**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~~~x~~~~~

**ក្រសួងពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
~~~~x~~~~

# របាយការណ៍ការងារ
# ប្រចាំឆ្នាំ ២០១០
# និង
# ទិសដៅការងារឆ្នាំ ២០១១

~~*~~

ដោយមានការខិតខំព្យាយាមក្នុងការងាររបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងដោយមានការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មទាំងផ្នែកស្មារតី និង សំភារៈ រួមទាំងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នជាតិ-អន្តរជាតិនានាផងនោះ ធ្វើអោយដំណើរការ កែលំអរ និងលើកកំពស់ការអនុវត្តវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាកាន់តែមានភាពរឹងមាំ និងល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ដែលជាការរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ សកម្មភាពជាក់ស្តែងក្នុងឆ្នាំ ២០១០ នេះ នាយកដ្ឋានទទួលបានលទ្ធផលការងារដូចខាងក្រោម:

## I. <u>លទ្ធផលការងារដែលទទួលបាន</u>

### ក_ការងាររៀបចំច្បាប់ និង បទបញ្ញត្តិនានា

#### ក១. ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម

ដោយមានការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន និង ដោយមានការជួយឧបត្ថម្ភគាំទ្រពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម នៅឆ្នាំ ២០១០ កន្លងមកនេះ នាយកដ្ឋានសម្រេចបាននូវ ការរៀបចំច្បាប់ និង បទប្បញ្ញត្តិនានា ដូចខាងក្រោម :

-សេចក្តីព្រាងច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានដាក់ឆ្លងក្នុងរបៀបវារៈកិច្ចប្រជុំរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញារួចជាស្ថាពរ នៅសល់តែជំពូកទី១៤ ទាក់ទងនឹងទោសប្បញ្ញត្តិដែលតម្រូវឱ្យមានការបកស្រាយឱ្យបានច្បាស់លាស់ពីក្រសួងយុត្តិធម៌ ។ បន្ទាប់ពីមានការឆ្លើយតបជាផ្លូវការពីក្រសួងយុត្តិធម៌រួចហើយ សេចក្តីព្រាងច្បាប់នេះនឹងត្រូវបញ្ជូនទៅ ទីស្តីការគណៈរដ្ឋមន្ត្រី នាពេលវេលាសមស្របណាមួយ ។

-ព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និង អនុគណៈកម្មាធិការអប់រំ និង ផ្សព្វផ្សាយរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ។

- អនុសារណៈនៃការយោគយល់ (MoU) របស់ក្រុមហ៊ុន Microsoft

-សេចក្តីព្រាង សេចក្តីសម្រេចស្តីពីការបង្កើតអនុក្រុមការងាររបស់សរសរស្តម្ភ (Pillar1) សម្រាប់អនុវត្តកម្មវិធីអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម (TRADE SWAP) ហើយត្រូវបានចុះហត្ថលេខារួចហើយ នៅថ្ងៃទី 03/12/10 ។

-បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មាធិការ អប់រំ និងផ្សព្វផ្សាយ ហើយបានត្រៀមផ្ញើរទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បី ពិនិត្យ និងសម្រេច ។

-បានរៀបចំសេចក្តីព្រាងប្រកាស ស្តីពីភ្នាក់ងាតំណាងម្ចាស់ម៉ាកស្របច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

-បានពិនិត្យ និងរៀបចំសេចក្តីព្រាងប្រកាសស្តីពីនិតិវិធីចុះបញ្ជី និងគ្រប់គ្រងម៉ាក ។

**ក២.ក្នុងក្របខ័ណ្ឌអន្តរក្រសួង**

-បានផ្ញើសេចក្តីព្រាងច្បាប់ ស្តីពីអាជ្ញាប័ណ្ណបញ្ជាសំរាប់សុខភាពសាធារណៈ ទៅក្រសួងសុខាភិបាល និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីពិនិត្យ និងដាក់ជូនទៅរាជរដ្ឋាភិបាល ។

-បានសហការណ៍ជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ លើសំណើរបស់សហរដ្ឋអាមេរិច ចំពោះសេចក្តីព្រាងតុបករណ៍ (Consensus Instrument) ផ្លូវការសំរាប់ជនពិការ ។

## ខ. ការងារផ្សព្វផ្សាយ និង សហប្រតិបត្តិការអន្តរជាតិ

### ខ១-ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាល

នាយកដ្ឋានបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការផ្សព្វផ្សាយ និង ការពង្រឹងការការពារកម្មសិទ្ធិបញ្ញានៅតាមស្រទាប់ សិស្ស និស្សិត ប្រជាជន ក៏ដូចជាអាជីវករទាំងអស់ ដើម្បីធ្វើអោយពួកគេកាន់តែមានការយល់ដឹងស៊ីជម្រៅពីកម្មសិទ្ធិបញ្ញា និង ចូលរួមលើកស្ទួយការការពារកម្មសិទ្ធិបញ្ញានៅកម្ពុជា ។ នៅឆ្នាំ ២០១០ នេះ នាយកដ្ឋានបានបណ្តុះបណ្តាលអំពីមុខជំនាញ កម្មសិទ្ធិបញ្ញាក្នុងនិងក្រៅប្រទេស ជូនដល់មន្ត្រីនាយកដ្ឋាន ក្រសួងពាក់ព័ន្ធ អាជីករ សាធារណជន ដោយមានការជួយឧបត្ថម្ភ ពិបណ្តាប្រទេសជាមិត្ត និង អង្គការអន្តរជាតិនានា ។ ការងារបណ្តុះបណ្តាលនេះ មានដូចខាងក្រោម :

### ខ១-១-រៀបចំសិក្ខាសាលាបំប៉នជំនាញកម្មសិទ្ធិបញ្ញា ក្នុងប្រទេស

នាយកដ្ឋានបានអញ្ជើញមន្ត្រីអន្តរក្រសួងពាក់ព័ន្ធ ភ្នាក់ងារកម្មសិទ្ធិបញ្ញា និង និស្សិត ចូលរួមសិក្ខាសាលា :

-ការប្រើប្រាស់ពតិមាន Patent សំរាប់បង្កើនសមត្ថភាពបច្ចេកទេស

-Disposal of Goods នៅខេត្តសៀមរាប ក្រោមកិច្ចសហការ របស់អង្គការ WIPO និង USPTO ។

-ច្បាប់កម្មសិទ្ធិបញ្ញាអន្តរជាតិ ច្បាប់ម៉ាក ច្បាប់ប្រកួតប្រជែងអន្តរជាតិ និង កិច្ចប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ

-ផ្សព្វផ្សាយទស្សនទានការសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងប្រទេស

**១១-២-បញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលានៅក្រៅប្រទេស**

-សរុបចំនួនសិក្ខាសាលា ដែលបានចូលរួម ចំនួន ៤៧ លើក

-សរុបសិក្ខាកាម ដែលបានចូលរួម ចំនួន ១០៩ នាក់

*ដែលក្នុងនោះ*

-មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ចំនួន ៤៦ នាក់

-មន្ត្រីអង្គភាពពាក់ព័ន្ធ ចំនួន ៦៣ នាក់

**១២-ការងារសហប្រតិបត្តិការអន្តរជាតិ**

ដោយមានកិច្ចសហប្រតិបត្តិការពីទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ **(AFD)** និងវិទ្យាស្ថានជាតិ នៃការហៅប្រភពដើម **(INAO)** ប្រទេសបារាំង បានផ្តល់ជំនួយបច្ចេកទេស ដែលមានទឹកប្រាក់សរុបចំនួន មួយលាន អឺរ៉ូ **(1.000.000)** ដើម្បីអនុវត្តគម្រោងនាំមុខសម្រាប់ការការពារការសម្គាល់ភូមិសាស្ត្រនៅកម្ពុជា **"ផលិតផលម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ "**។ ផលិតផលទាំងពីរមុខនេះ ត្រូវបានចុះបញ្ជីទទួលស្គាល់នៅក្រសួងពាណិជ្ជកម្ម នាថ្ងៃទី ០២ ខែ មេសា ២០១០ ។ ជំនួយបច្ចេកទេសនេះ ក៏មានគោលបំណងដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពី **ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** ដែលជាច្បាប់មួយ សម្រាប់ជួយលើកស្ទួយវប្បធម៌ ប្រពៃណីជនជាតិខ្មែរយើង តាមរយៈការចងក្រងជាសមាគមផលិតទំនិញ ដែលមានសក្តានុពល ផ្សារភ្ជាប់ទៅនឹងទីកន្លែងផលិតរបៀបផលិត ស្ថានភាពដី ដែលធ្វើឱ្យផលិតផល មានគុណភាពពិសេសខុសប្លែកពីផលិតផលដទៃទៀត ហើយលក់បានតម្លៃខ្ពស់ជាងតម្លៃផលិតផលធម្មតា ដែលពុំមានពាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។ ការបង្កើតច្បាប់នេះឡើងក្នុងគោលបំណងការពារទ្រព្យសម្បត្តិខាងបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងការពារអ្នកប្រើប្រាស់ផលិតផល ដែលពាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញព្រមទាំងរក្សា និង ពង្រឹងចំណេះដឹង ចំណេះធ្វើជាប្រពៃណីពីបូរាណ និងជាអត្តសញ្ញាណជាតិ ដើម្បីបង្កើតការងារនៅតាមជនបទ អភិវឌ្ឍន៍សហគមន៍ ទាក់ទាញភ្ញៀវទេសចរ និងកាត់បន្ថយភាពក្រីក្រ ។

ជាលទ្ធផល យើងបានពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយសមាជិក លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិកម្មសិទ្ធិបញ្ញា ចប់ជាស្ថាពរ និង បានចុះបញ្ជីទទួលស្គាល់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ លើផលិតផលចំនួនពីរមុខ គឺ **ផលិតផលម្រេចកំពត និងផលិតផល ស្ករត្នោតកំពង់ស្ពឺ** ក្រោមប្រកាស ស្តីពី **នីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ ភូមិសាស្ត្រទំនិញ ។**

កន្លងមក ក្រោមជំនួយឧបត្ថម្ភរបស់អង្គការ OXfam ប្រចាំខេត្តក្រចេះ និងសហគមន៍អភិវឌ្ឍន៍កម្ពុជា (CCD) នាយកដ្ឋានក៏បានចុះទៅធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវជាបឋម អំពី អង្ករនាងអំក្រចេះ នៅឃុំ ស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ក្នុង

គោលបំណងដាក់ផលិតផលនេះ ជាផលិតផលសម្គាល់ភូមិសាស្ត្រ ក្រោមការការពារដោយច្បាប់ ស្តីពី **"ម៉ាកសម្គាល់ភូមិសាស្ត្រ ទំនិញ"** ។

-របាយការណ៍របស់ UNCTAD-ICTSD លើ Development Dimensions of Intellectual Property in Cambodia: Copyright, Growth, Education and Culture

- ការងាររបស់ក្រុម Pillar 1 ក្រោមអធិបតីយភាព ឯកឧត្តម ប៉ាន សូរស័ក្តិ

-ការបង្កើតអនុក្រុមការងាររបស់ Pillar 1

- Road Map របស់ Pillar 1

-Pillar1 Output Indication ជាមួយ Consultant របស់ធនាគារពិភពលោក និងកិច្ចប្រជុំចម្រុះរវាងក្រុមការងារ Pillar 1, Pillar 3 និង Consultant របស់ធនាគារពិភពលោក ដោយផ្តោតទៅលើ :

-ការវាយតម្លៃពីការរីកចំរើននៅក្នុង TDSP

-ការវាយតម្លៃអំពីភាពអាចធ្វើបាននៃសកម្មភាពនៅក្នុងគំរោងនាពេលអនាគត

-ប្រសិនបើចាំបាច់ រៀបចំរចនាសម្ព័ន្ធឡើងវិញនៃទិដ្ឋភាពអនុវត្ត TDSP

-គំរោងអាស៊ាន ស្តីពីការការពារកម្មសិទ្ធិបញ្ញា (ECAP III)

## គ-កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

### គ១-ធនធានមនុស្ស

ក្នុងឆ្នាំ ២០១០ នេះ នាយកដ្ឋានមានមន្ត្រីរាជការសរុបចំនួន ៦២ រូប ក្នុងនោះមន្ត្រីថ្នាក់នាយកដ្ឋានមានចំនួន ០៥ រូប និងថ្នាក់ការិយាល័យមានចំនួន ២៤ រូប ។

### គ២-ការងារថវិកា

ដោយគិតចាប់ពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ រហូតដល់ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០ នាយកដ្ឋានបានរកចំណូល បង់ជូននាយកដ្ឋានរដ្ឋបាលសរុប ចំនួន **923,340,000.00៛** ( ប្រាំបួនរយម្ភៃបីលានបីរយសែសិបពាន់រៀល) ដែលក្នុងនោះមាន :

| | | |
|---|---|---|
| - កំរៃនៃការដាក់ពាក្យសុំចុះបញ្ជីម៉ាក | : | 79,380,000.00៛ |
| - កំរៃនៃការចុះបញ្ជីម៉ាក | : | 546,480,000.00៛ |
| - កំរៃនៃការបញ្ជាក់ ការប្រើប្រាស់ម៉ាក | : | 60,560,000.00៛ |
| - កំរៃនៃការផ្ទេរកម្មសិទ្ធិម៉ាក | : | 13,840,000.00៛ |
| - កំរៃនៃការប្តូរឈ្មោះម្ចាស់ម៉ាក | : | 17,800,000.00៛ |
| - កំរៃនៃការកែតំរូវនានា | : | 840,000.00៛ |
| - កំរៃនៃការក្នុងការប្តូរអស័យដ្ឋាន | : | 15,640,000.00៛ |
| - កំរៃក្នុងការលុបម៉ាកចេញពីបញ្ជី | : | 6,400,000.00៛ |

- កំរៃក្នុងការចុះបញ្ជីសាឡើងវិញ : 182,400,000.00៛

**សរុប: 923,340,000.00៛**

**ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក និង ចំណូល ចាប់ពីឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១០**

| ល.រ | មុខចំណូល | | 2009 | | 2010 | |
|---|---|---|---|---|---|---|
| | | | ចំនួនម៉ាក | ទឹកប្រាក់ | ចំនួនម៉ាក | ទឹកប្រាក់ |
| 1 | ដាក់ពាក្យ | ក្នុងស្រុក | 806 | 16120000 | 840 | 16800000 |
| | | ក្រៅស្រុក | 2271 | 45420000 | 3129 | 62580000 |
| | | **សរុប** | **3077** | **61540000** | **3969** | **79380000** |
| 2 | ចុះបញ្ជីម៉ាក | ក្នុងស្រុក | 698 | 125640000 | 652 | 117360000 |
| | | ក្រៅស្រុក | 2418 | 435240000 | 2384 | 429120000 |
| | | **សរុប** | **3116** | **560880000** | **3036** | **546480000** |
| 3 | ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ម៉ាក | | 1954 | 78160000 | 1514 | 60560000 |
| 4 | ការផ្ទេរសិទ្ធិម្ចាស់ម៉ាក | | 327 | 13080000 | 346 | 13840000 |
| 5 | ការប្តូឈ្មោះ រឺបញ្ចូលគ្នានៃម្ចាស់ម៉ាក | | 599 | 23960000 | 445 | 17800000 |
| 6 | ការកែតំរូវ | | 28 | 1120000 | 21 | 840000 |
| 7 | ការប្តូឈ្មោះអាស័យដ្ឋាន | | 309 | 12360000 | 391 | 15640000 |
| 8 | ការលុបម៉ាក | | 11 | 2200000 | 32 | 6400000 |
| 9 | ការចុះបញ្ជីម៉ាកសាឡើងវិញ | | 689 | 137800000 | 912 | 182400000 |
| 10 | **សរុប** | | | **891100000** | | **923340000** |

ឯកតាគិត ជារៀល

**សន្និដ្ឋាន :**

យើងឃើញថា នៅក្នុងឆ្នាំ ២០១០ កន្លងមកនេះ នាយកដ្ឋានបានរកចំណូលបង់ជូនរដ្ឋសរុបចំនួន **923,340,000.00៛** ហើយបើប្រៀបធៀបទៅនឹងការបង់ចំណូលជូនរដ្ឋក្នុងឆ្នាំ ២០០៩ បានចំនួន **891,100,000.00៛** យើងឃើញថា មានការកើនឡើងចំនួន **32,240,000.00៛** ស្មើនឹង 3,6% ។ ប៉ុន្តែបើប្រៀបធៀបទៅនឹងផែនការរកចំណូលឆ្នាំ ២០១០ (1,090,000,000៛) នាយកដ្ឋាន អនុវត្តបានចំនួន 84,71% នៃផែនការតែប៉ុណ្ណោះ ។

## ឃ-កិច្ចការជំនាញពាណិជ្ជសញ្ញា

### ឃ១-ការចុះបញ្ជីពាណិជ្ជសញ្ញា

គិតរហូតមកដល់ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០ នាយកដ្ឋានបាន :

#### ឃ១-១-ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកថ្មី

-ទទួលពាក្យក្នុងស្រុកសរុបចំនួន 840 ម៉ាក

-ទទួលពាក្យបរទេសសរុបចំនួន 3 129 ម៉ាក

#### ឃ-១-២-ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មី

-ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មីក្នុងស្រុកចំនួន 652 ម៉ាក

- ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មីបរទេសចំនួន 2 384 ម៉ាក

#### ឃ-១-៣-កិច្ចការក្រោយចុះបញ្ជី :

| | |
|---|---|
| -ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ម៉ាក : | 1 514 ម៉ាក |
| -ការផ្ទេរសិទ្ធិ ម្ចាស់ម៉ាក : | 346 ម៉ាក |
| -ការប្តូរឈ្មោះ រឺបញ្ចូលគ្នានៃម្ចាស់ម៉ាក : | 445 ម៉ាក |
| -ការកែតម្រូវ : | 21 ម៉ាក |
| -ការប្តូរឈ្មោះអាសយដ្ឋាន : | 391 ម៉ាក |
| -ការលុបម៉ាក : | 32 ម៉ាក |
| -ការចុះបញ្ជីម៉ាកឡើងវិញ : | 912 ម៉ាក |

**សន្និដ្ឋាន :**

ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកថ្មីនៅឆ្នាំ ២០១០នេះ នាយកដ្ឋានបានទទួលសរុបចំនួន **៣៩៦៩ម៉ាក** ក្នុងនោះម៉ាកក្នុងស្រុកមានចំនួន 840 **ម៉ាក** ម៉ាកក្រៅស្រុកមានចំនួន 3129 **ម៉ាក**។ ។ បើប្រៀបធៀបទៅនឹងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកថ្មីឆ្នាំ ២០០៩ សរុបចំនួន 3077 ម៉ាក យើងឃើញថា នៅក្នុងឆ្នាំ ២០១០ នេះ មានការកើនចំនួន 892 ម៉ាក ស្មើនឹង 29 % ភាគរយ ។ ការកើនឡើងនេះ បង្ហាញអោយឃើញថាសាធារណជន ទាំងនៅក្នុងប្រទេស និងក្រៅប្រទេសមានជំនឿ និងទុកចិត្តចំពោះនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ដែលតែងតែយកចិត្តទុកដាក់ក្នុងការអនុវត្ត និងផ្សព្វផ្សាយច្បាប់ ។ ទន្ទឹមនឹងនោះ ការយល់ដឹងពីអត្ថប្រយោជន៏ក្នុងការចុះបញ្ជីម៉ាក របស់អាជីវករ ផលិតករ កម្ពុជាយើង មានការយល់ ដឹងពីសារៈសំខាន់នៃការចុះបញ្ជីម៉ាករបស់ខ្លួន នេះបង្ហាញអោយឃើញថា សហគ្រាសធនតូច និងមធ្យមរបស់កម្ពុជាបានផលិតទំនិញ ផ្គត់ផ្គង់ទីផ្សារកម្ពុជាកាន់តែច្រើនឡើង ហេតុដូចនេះធ្វើអោយសេដ្ឋកិច្ចកម្ពុជាមានភាពរឹងមាំ និងកាន់តែមានភាពរីកចំរើន សំដៅទៅរកទីផ្សារប្រកួតប្រជែងទាំងក្នុងស្រុក ក្នុងតំបន់ និងសាលកលោក ។

ចំណែកឯការឯកភាពចុះបញ្ជីម៉ាកជូនអតិថិជននៅឆ្នាំ ២០១០ នេះ នាយកដ្ឋានបានឯកភាពចុះបញ្ជីម៉ាក សរុបចំនួន 3036 **ម៉ាក** ក្នុងនោះម៉ាកក្នុងស្រុក ចំនួន 652 **ម៉ាក** ម៉ាកក្រៅស្រុកចំនួន 2384 **ម៉ាក** ហើយបើប្រៀបធៀបទៅនឹងការចុះបញ្ជី ម៉ាកក្នុងឆ្នាំ២០០៩ ទទួលបានចំនួន 3116ម៉ាក យើងឃើញថាមានការថយចុះចំនួន 80ម៉ាក ស្មើនឹង -2,6% ។ ការថយចុះនេះ បណ្តាលមកពីការត្រួតពិនិត្យម៉ាកមានលក្ខណៈកាន់តែលំអិត និងស៊ីជម្រៅ ស្របទៅតាមស្តង់ដាអន្តរជាតិ ។

### ខ_ការខារបោះពុម្ពផ្សាយព្រឹត្តិបំត្រផ្លូវការ

ជាផ្នែកមួយតម្រូវដោយច្បាប់ ដើម្បីអោយការចុះបញ្ជីម៉ាកមានតម្លាភាព និងទុកលទ្ធភាពអោយភាគីទី៣ មាន សិទ្ធិប្តឹងជំទាស់ទៅនឹងការចុះបញ្ជីម៉ាក នាយកដ្ឋានបានបោះពុម្ពព្រឹត្តិប័ត្រផ្លូវការ (Official Gazette) បានសរុបចំនួន ១២ លេខ គឺ ពីលេខ ១១៩ ដល់ ១៣០ ដើម្បីផ្សព្វផ្សាយជាសាធារណៈ ។

### ច_ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និង ការលុបម៉ាកចេញពីបញ្ជី

## k). kargarTTYlBakü

ក្នុងឆ្នាំ ២០១០ នេះ ការិយាល័យវិវាទបានទទួលពាក្យបណ្តឹងសរុបចំនួន ៥៩ករណី ក្នុងនោះ រួមមានពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពាន (សូមមើលតារាង **ក**) មានចំនួន ២៨ ករណី ស្មើនឹង ៤៧% និងពាក្យស្នើសុំលុបម៉ាក (សូមមើលតារាង **ខ**) មានចំនួន ៣១ ករណី ស្មើនឹង ៥៣% នៃការទទួល ពាក្យបណ្តឹងសរុប ។

### **ខ). លទ្ធផលនៃការដោះស្រាយ**

### ១-ការដោះស្រាយការរំលោភបំពាន

ក្នុងឆ្នាំ ២០១០ នេះ ការិយាល័យវិវាទបានពិនិត្យពាក្យបណ្តឹងចំនួន **៣៥** ករណី (ក្នុងឆ្នាំ ២០១០ ទទួលបានចំនួន **២៨** ករណី និងសល់ពីឆ្នាំ ២០០៩ ចំនួន **៧**ករណី) និងបានដោះស្រាយការរំលោភបំពានបាន ចំនួន **៣២**ករណី ក្នុងនោះរួមមាន ការធ្វើការសំរបសំរួលដោយមានកំណត់ហេតុចំនួន **១២** ករណី ធ្វើលិខិត បញ្ជាក់ពីភាពស្រដៀងនាំឱ្យភាន់ច្រឡំមានចំនួន **១០** ករណី ធ្វើលិខិតបញ្ជាក់អំពីការប្រើប្រាស់ចំនួន **១**ករណី ធ្វើលិខិតព្រមានជាសាធារណៈចំនួន **១**ករណី កែតំរូវចំនួន **១**ករណី បដិសេធចំនួន **៥**ករណី និងដកពាក្យ បណ្តឹងដោយដើមបណ្តឹងវិញចំនួន **២**ករណី ដោយសារម្ចាស់ម៉ាកបានប្តូរជំហរ ហើយនៅសល់ **៣**ករណីទៀត ការិយាល័យកំពុងបន្តពិនិត្យ និងដោះស្រាយ (សូមមើលតារាង **ក**) ។

### ២-ការលុបម៉ាកចេញពីបញ្ជី

ក្នុងឆ្នាំ ២០១០ នេះ ការិយាល័យវិវាទបានពិនិត្យពាក្យស្នើសុំលុបម៉ាកចំនួន **៤៥**ករណី (ក្នុងឆ្នាំ ២០១០ ទទួលបានចំនួន **៣១**ករណី និង នៅសល់ពីឆ្នាំ ២០០៩ ចំនួន **១៤**ករណី) និងបានដោះស្រាយចំនួន **២៥**ករណី ក្នុងនោះរួមមាន ការលុបម៉ាកចេញពីបញ្ជីចំនួន **២១**ករណី ស្មើ **៣១**ម៉ាក កែតំរូវម៉ាកសាជាថ្មីចំនួន **១**ករណីស្មើ **១**ម៉ាក កែតំរូវនាមករណ៍ក្រុមហ៊ុន **១** និងនាយកដ្ឋានបានចេញលិខិតមោឃភាព **១**ករណី ស្មើ **១**ម៉ាក ព្រោះម្ចាស់ម៉ាកបានផ្ទេរកម្មសិទ្ធិដោយខុសច្បាប់ ហើយដើមបណ្តឹង

ដកពាក្យវិញចំនួន **១**ករណី ស្មើ **១**ម៉ាក នៅសល់ **២០**ករណី ស្មើ **២៧**ម៉ាក ការិយាល័យកំពុងបន្តពិនិត្យ និងដោះស្រាយ (សូមមើលតារាង ២)។

### **គ). ការប្រៀបធៀប**

បើធ្វើការប្រៀបធៀបការទទួលពាក្យស្នើសុំទប់រំលោភបំពានពាណិជ្ជសញ្ញាក្នុងឆ្នាំ ២០១០ នេះ នឹងឆ្នាំ ២០០៩ គឺ កើនឡើងចំនួន **១៤** ករណី ឬកើនឡើង ១០០% ហើយការទទួលពាក្យស្នើសុំលុបម៉ាក ចេញពីបញ្ជីក៏កើនឡើងចំនួន **១៧** ករណី ឬកើនឡើង ១២១% ផងដែរ។ ចំណែកលទ្ធផលនៃការដោះស្រាយ ការរំលោភបំពានក្នុងឆ្នាំ ២០១០ មានចំនួន **៣២** ករណី បើធៀបនឹងឆ្នាំ ២០០៩ គឺកើនឡើងចំនួន **២០** ករណី ឬកើនឡើង ១៦៧% ។ ដោយឡែកការលុបម៉ាកចេញពីបញ្ជីក្នុងឆ្នាំ ២០១០ នេះ មានចំនួន **៣១**ម៉ាក បើធៀបនឹងឆ្នាំ ២០០៩ គឺកើនឡើងចំនួន **២០** ម៉ាក ឬកើនឡើង ១៨២%។




ទោះបី សកម្មភាពរំលោភបំពានម៉ាក នៅក្នុងឆ្នាំ ២០១០ មានការកើនឡើងក៏ដោយ ក៏នេះ មិនមែនជាសូចនាករមួយឆ្លុះបញ្ចាំងពីសកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញា ក្នុងប្រទេសកម្ពុជានោះឡើយ ប៉ុន្តែវាជាសូចនាករមួយជ្រុង បង្ហាញអោយឃើញថា សកម្មភាពរំលោភបំពាននៃម៉ាកមានការកើនឡើង ហើយសកម្មភាពពាណិជ្ជកម្ម មានភាពរីកលូតលាស់កាន់តែប្រសើរឡើង ទន្ទឹមនឹងនេះ ការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា ក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជ្រាបចូលក្នុងស្រទាប់មហាជនកាន់តែប្រសើរឡើង ហើយម្ចាស់កម្មសិទ្ធិបញ្ញា បានចាប់អារម្មណ៍ដល់ការការពារផលប្រយោជន៍ ដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ដោយផ្តួចផ្តើមចាត់វិធានការចំពោះការរំលោភបំពានទាំងនោះ ទៅតាមស្ថាប័នអនុវត្តកម្មសិទ្ធិបញ្ញា ដែលមានស្រាប់។

### **សន្និដ្ឋាន**

ថ្វីត្បិតតែការិយាល័យវិវាទ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ខិតខំបំពេញការងាររបស់ខ្លួន បាននាំ មកនូវការវិវត្តន៍ដ៏ល្អប្រសើរក៏ដោយ ក៏ការិយាល័យនេះ នៅមានការងារជាច្រើនទៀត ត្រូវបំពេញអោយ បានទាន់ការវិវត្តន៍នៃកម្មសិទ្ធិបញ្ញាជាសកល និងការរីករាលដាលនៃការរំលោភបំពានកម្មសិទ្ធិបញ្ញា ទាមទារ អោយមានមន្ត្រីដែលមានសមត្ថភាពមកបំរើការងារបន្ថែមទៀត។

សកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា នៅតែជាបញ្ហាគួរឱ្យកត់សម្គាល់នៅ ឡើយ ហើយការអនុវត្តន៍កម្មសិទ្ធិបញ្ញាមិនអាចប្រព្រឹត្តទៅបានដោយរលូនទេ ប្រសិនបើម្ចាស់កម្មសិទ្ធិបញ្ញា នៅតែប្រងើយកន្តើយចំពោះការរំលោភបំពានទាំងនោះ គួរតែម្ចាស់កម្មសិទ្ធិបញ្ញាសហការជាមួយសមត្ថកិច្ច ដើម្បីធ្វើការទប់ស្កាត់ការរំលោភបំពានអោយកាន់តែមានប្រសិទ្ធិភាព ដើម្បីលើកស្ទួយការបង្កើតសម្បត្តិ កម្មសិទ្ធិបញ្ញា ក្នុងការចូលរួមចំណែក អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

**តារាង ក**

| ស្ថិតិនៃការរំលោភបំពានកម្មសិទ្ធិបញ្ញាក្នុងឆ្នាំ ២០១០ | | | | |
|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | ការដោះស្រាយ | | នៅសល់ |
| | | ការដក និង បដិសេធពាក្យបណ្តឹង | ការបញ្ជាក់ផ្សេងៗ ចេញលិខិតព្រមាន កែតំរូវ សំរបសំរួល និង បញ្ជាក់ភាពស្រដៀង | |
| ២០០៩ | | | | ៧ |
| ២០១០ | ២៨ | ៧ | ២៥ | |
| **សរុប** | **៣៥** | **៧** | **២៥** | **៣** |

**តារាង ខ**

| ស្ថិតិនៃការលុបម៉ាកក្នុងឆ្នាំ ២០១០ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | | ការដោះស្រាយ | | | | | | នៅសល់ | |
| | | | ការបដិសេធន៍ និង ដកពាក្យបណ្តឹង | | លុប | | មោឃភាព កែតំរូវ | | | |
| | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក |
| ២០០៩ | | | | | | | | | **១៤** | **១៧** |
| ២០១០ | ៣១ | ៤៦[1] | ១ | ១ | ២១ | ៣២ | ៣ | ៣ | | |
| **សរុប** | **៤៥** | **៦៣**[2] | **១** | **១** | **២១** | **៣២**[3] | **៣** | **៣**[4] | **២០** | **២៧** |

*១: ៤៥ម៉ាក និងនាមករណ៏ក្រុមហ៊ុន ១ ។*

*២: ៦២ម៉ាក និងនាមករណ៏ក្រុមហ៊ុន ១ ។*

*៣: ក្នុងចំណោម ៣២ម៉ាកនេះ មានពាក្យស្នើសុំលុបម៉ាក ចំនួន ០២ បាន ស្នើសុំលុបតែម៉ាក ១ ដែលមានលេខចុះបញ្ជីដូចគ្នា ដូច្នេះក្នុងឆ្នាំ ២០១០ លុបបាន ៣១ ម៉ាក ។*

*៤: មោឃភាព ១ ម៉ាក កែតំរូវ ១ម៉ាក និងកែតំរូវនាមករណ៏ក្រុមហ៊ុន ១*

*__សំគាល់__ រាល់ពតិមានលំអិត ស្តីពីការទទួលពាក្យ ការដោះស្រាយការរំលោភបំពាន និងការលុបម៉ាកចេញពីបញ្ជី មានតំកល់នៅ ការិយាល័យវិវាទ ។*

## II-ទិសដៅអនុវត្តការងារសំរាប់  ឆ្នាំ  ២០១១

ក្នុងឆ្នាំ ២០១១នេះ នាយកដ្ឋានមានទិសដៅអនុវត្តការងារ ដូចខាងក្រោម :

### ក-ការងារកសាងច្បាប់  និងបទបញ្ញត្តិនានា

**ក១-**បន្តសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីបញ្ចប់ឱ្យបានឆាប់ នូវសេចក្តីព្រាងច្បាប់ស្តីពី **"ម៉ាកសម្គាល់ភូមិសាស្រ្ត ទំនិញ"** និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី  តាមវេលាសមស្របណាមួយ ។

**ក២-**បន្តសហការជាមួយនាយកដ្ឋាន និងក្រសួងពាក់ព័ន្ធ ដើម្បីពិនិត្យមើល ឡើងវិញនូវសេចក្តីព្រាងច្បាប់ ស្តីពីព័ត៌មាន សម្ងាត់ពាណិជ្ជកម្ម ដែលបានចងក្រងឡើង ក្រោមជំនួយបច្ចេកទេស ពីទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសកាណាដា (CIDA) ដើម្បីឆ្លងសេចក្តីព្រាងច្បាប់នេះ ទៅទីស្តីការគណៈរដ្ឋមន្ត្រី តាមពេលវេលាសមស្របណាមួយ។

**ក៣**-បន្តរៀបចំសេចក្តីប្រកាសស្តីពីនិតិវិធីចុះបញ្ជីម៉ាក និងគ្រប់គ្រងម៉ាក ។

**ក៤**-សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិ នៃការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ (MADRID SYSTEM)

### ខ-ការងារកិច្ចសហប្រតិបត្តិការ

**ខ១-**បន្តសហការជាមួយអាជ្ញាធរដែនដី និងក្រសួងជំនាញដែលមានការពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងកំណត់តំបន់ភូមិសាស្រ្តផលិតផលដែលមានសក្តានុពល ដើម្បីឈានទៅដល់ការចុះបញ្ជីការពារ ជាផលិតផលសម្គាល់ភូមិសាស្រ្ត នាថ្ងៃអនាគត ។

**ខ២-**ជម្រុញការសិក្សាបន្ថែម និងស្វែងរកដៃគូផ្តល់ជំនួយ លើផលិតផលដែលបានកំណត់ អត្តសញ្ញាណរួចហើយ ដូចជាអង្ករនាងអំក្រចេះ អង្ករបាត់ដំបង ប្រហុកសៀមរាប ក្រូចពោធិសាត់ ក្រវាញ ពោធិសាត់ សូត្រភ្នំស្រុក ទឹកឃ្មុំមណ្ឌលគីរី ធូរេនកំពត ជាដើម ដើម្បីឈានទៅរកការចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ។

**ខ៣-**រៀបចំសិក្ខាសាលាផ្សព្វផ្សាយទស្សនាទានផលិតផល សម្គាល់ភូមិសាស្រ្តច្បាប់ស្តីពី **"ម៉ាកសម្គាល់ភូមិសស្រ្តទំនិញ"** នៅពេលដែលច្បាប់នេះ ត្រូវបានអនុម័តដោយរដ្ឋសភារួចហើយ ក្នុង គោលដៅ ជម្រុញការចុះបញ្ជីផលិតផលសម្គាល់ភូមិសាស្រ្តទាំងក្នុង និងក្រៅប្រទេស ។

**ខ៤-**ត្រៀមរៀបចំធ្វើកិច្ចសហប្រតិបត្តិការជាមួយទីភ្នាកងារបារាំងដើម្បីការអភិវឌ្ឍន៍(AFD) និងអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO, Food and Agriculture of the United Nation) ដើម្បីអនុវត្តគម្រោងថ្នាក់តំបន់ ស្តីពី សម្គាល់ភូមិសាស្រ្តទំនិញ ដែលមានសមាជិកចំនួន 04 ប្រទេស គឺ កម្ពុជា វៀតណាម ឡាវ និង ថៃឡង់ដ៏ ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ និង ផ្លាស់ប្តូរចំណេះដឹង រវាងប្រទេសជាសមាជិក ក្នុងវិស័យសម្គាល់ភូមិសាស្រ្តទំនិញ នាពេលខាងមុខនេះ។

**ខ៥-**ត្រៀមរៀបចំបង្ហើយនីតិវិធីពាក់ព័ន្ធនានា ដើម្បីត្រៀមទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក សមូហភាព (Collective Mark) នាពេលដ៏ខ្លីខាងមុខនេះ ។

**៦៦**-រៀបចំ និងត្រៀមសហប្រតិបត្តិការជាមួយ កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម **(Trade Development Support Program, TDSP)** ដើម្បីស្នើសុំថវិកាមកអនុវត្តគម្រោងសិក្សាបឋមលើផលិតផលសក្តានុពលចំនួន ០២ មុខ គឺ ធូរេនកំពត និង អង្ករនាងអំក្រចេះ ក្នុងទិសដៅលើកជាគម្រោងសិក្សាលំអិតដើម្បីអាចចុះបញ្ជីការពារ ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

## គ_ការងារបច្ចេកទេសដែលទាក់ទង នឹងវិស័យកម្មសិទ្ធិបញ្ញា

នាយកដ្ឋានមានគោលការណ៍ធ្វើឱ្យទំនើបឡើង នូវប្រព័ន្ធគ្រប់គ្រង និងចុះបញ្ជីពាណិជ្ជសញ្ញាដោយៈ

-បន្តបញ្ចូលទិន្នន័យម៉ាក ដែលបានចុះបញ្ជីហើយទៅក្នុង Computer Database តាមប្រព័ន្ធ IPAS

-ពង្រឹងដំណើរការត្រួតពិនិត្យម៉ាកដោយស្វ័យប្រវត្តិ តាមរយៈ Computer ចំពោះម៉ាកជារូបភាព។

-បន្តរៀបចំកែលំអរប្រព័ន្ធចុះបញ្ជីម៉ាក តាមរយៈស្វ័យប្រវត្តិកម្ម (Computerization of Trademark Registration) អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ និង សុក្រឹត្យ។

-ជូនដំណឹងដល់អតិថិជន អោយមកចុះបញ្ជីម៉ាករបស់ខ្លួនសាជាថ្មី បន្ទាប់ពីបានចុះបញ្ជីរយពេល ១០ឆ្នាំ រួច។

-រៀបចំឱ្យមានមជ្ឈមណ្ឌលពត៌មានកម្មសិទ្ធិបញ្ញាមួយ សំរាប់បំរើដល់អតិថិជនដែលមានបំណង ចង់ស្វែងយល់ពី កម្មសិទ្ធិបញ្ញានិយាយរួម និង និយាយដោយឡែក ពីម៉ាកដែលបានចុះបញ្ជីរួចហើយ ឬ ឯកសារនានា ដែលទាក់ទង និង ការចុះបញ្ជីម៉ាក និង វិវាទនានានៅកម្ពុជា ។

-រៀបចំយន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់មហាជន និង អាជីវករ អំពីច្បាប់ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ជាពិសេសច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការក្រក្លួតប្រជែងមិនស្មោះត្រង់ ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេ ។

-រៀបចំបោះពុម្ពផ្សាយ នូវព្រឹត្តិប័ត្រផ្លូវការអោយបាន ចំនួន ១២លេខ ក្នុងមួយឆ្នាំ ព្រមទាំងបញ្ចូល ឯកសារទៅក្នុង CD ដើម្បីចែកជូនអតិថិជន ក្នុង និង ក្រៅប្រទេស ដែលបានចុះបញ្ជីការពារម៉ាក របស់ខ្លួននៅកម្ពុជា និង ខិតខំរៀបចំចងក្រងព្រឹត្តិប័ត្រផ្លូវការជា CDs ។

-ពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ដោយបង្កើនកិច្ចសហការអោយបានកាន់តែជិតស្និទ្ធិថែមទៀត ជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីកាត់បន្ថយការរំលោភកម្មសិទ្ធិបញ្ញាអោយបានជាអតិបរមា ។

-បង្កើនសមត្ថភាពយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា កុំព្យូទ័រ និង ភាសាអង់គ្លេស ដល់មន្ត្រីជំនាញរបស់ នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធតាមរយៈការបញ្ជូនទៅបណ្តុះបណ្តាលវគ្គហ្វឹកហ្វឺនក្នុង និង ក្រៅប្រទេស។

-បន្តរៀបចំគំរូពាក្យស្នើសុំ និង គំរូលិខិតស្នាមផ្សេងៗទៀត ជាភាសាខ្មែរ និង អង់គ្លេស ដើម្បីងាយស្រួលដល់ ការអនុវត្តការងារចុះបញ្ជីម៉ាក ឱ្យបានកាន់តែប្រសើរឡើងថែមទៀត។

-ជំរុញដោះស្រាយរាល់វិវាទទាក់ទិននឹង ការរំលោភបំពាន និងការលុបម៉ាក ដែលនៅសេសសល់

-បន្តបង្កើនកិច្ចសហការអោយកាន់តែជិតស្និទ្ធ និងមានលក្ខណៈកាន់តែប្រសើរឡើង ថែមទៀត ជាមួយអង្គភាពពាក់ព័ន្ធ និង ស្ថាប័នមានសមត្ថកិច្ចនានា ដើម្បីកាត់បន្ថយការរំលោភបំពាន កម្មសិទ្ធិបញ្ញា អោយបានជាអតិបរមា។

-រៀបចំរាល់ឯកសារវិវាទអោយមានលក្ខណៈជាប្រព័ន្ធកាន់តែប្រសើឡើង ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ

-បន្តតាមដានដាក់លក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាកដែលមានវិវាទ ក្នុងប្រព័ន្ធ IPAS ដើម្បីធានា ដល់ប្រសិទ្ធភាពការងារ របស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

-បង្កើនសមត្ថភាពយល់ដឹង លើផ្នែកភាសាអង់គ្លេស កុំព្យូទ័រ និងកម្មសិទ្ធិបញ្ញា ដល់មន្ត្រី ក្នុងនាយកដ្ឋន តាមរយៈការបញ្ជូនទៅសិក្សាទាំងនៅក្នុង និងក្រៅប្រទេស។

-បន្តរក្សាសាមគ្គីភាពផ្ទៃក្នុងល្អៗ រវាងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។

ភ្នំពេញ.ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១០

**អនុប្រធាននាយកដ្ឋាន**

**ស៊ឹម សុខខេង**